ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# គោលនយោបាយ
# ស្តីពី
# ការអភិវឌ្ឍការស្រាវជ្រាវ
# ក្នុងវិស័យអប់រំ

បានទទួលការឯកភាព
ក្នុងកិច្ចប្រជុំថ្នាក់ដឹកនាំក្រសួងនាថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ២០១០

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# គោលនយោបាយ

ស្តីពី

# ការអភិវឌ្ឍការស្រាវជ្រាវ

# ក្នុងវិស័យអប់រំ

*បានទទួលការឯកភាព*

*ក្នុងកិច្ចប្រជុំថ្នាក់ដឹកនាំក្រសួងនាថ្ងៃទី ០១ ខែកក្កដា ឆ្នាំ២០១០*

# មាតិកា


ទំព័រ

**បុព្វកថា** ii

**សេចក្តីផ្តើម** 1

**ជំពូកទី១** : **ចក្ខុវស័យ គោលដៅ និងគោលបំណង** 3

- I- **ចក្ខុវស័យ** 3
- II- **គោលដៅ** 3
- III- **គោលបំណង** 3

**ជំពូកទី២** : **គោលនយោបាយ** 3

**ជំពូកទី៣** : **យុទ្ធសាស្ត្រនិងការអនុវត្ត** 4

- I- **យុទ្ធសាស្ត្រ:** 4
  - **យុទ្ធសាស្ត្រទី១** : **អភិវឌ្ឍន៍សមត្ថភាពស្រាវជ្រាវ** 4
  - **យុទ្ធសាស្ត្រទី២** : **គុណភាពស្រាវជ្រាវ** 4
  - **យុទ្ធសាស្ត្រទី៣** : **ការស្រាវជ្រាវរួមគ្នា** 4
  - **យុទ្ធសាស្ត្រទី៤** : **របាយការណ៍ស្រាវជ្រាវ** 4
  - **យុទ្ធសាស្ត្រទី៥** : **ក្រមសីលធម៌ស្រាវជ្រាវនិងការអនុញ្ញាតឱ្យស្រាវជ្រាវ**
  - **យុទ្ធសាស្ត្រទី៦** : **សហប្រតិបត្តិការអន្តរជាតិ** 5
  - **យុទ្ធសាស្ត្រទី៧** : **ការសិក្សាទីផ្សារនិងអភិវឌ្ឍន៍** 5
- II- **ការអនុវត្ត** 5

**សន្និដ្ឋាន** 6

# បុព្វកថា

អនុលោមតាមច្បាប់ស្តីពីការអប់រំនៃព្រះរាជាណាចក្រកម្ពុជាមាត្រា១៨ ស្តីពីការ អប់រំឧត្តមសិក្សាបានកំណត់អំពីការជំរុញការស្រាវជ្រាវផ្នែកវិទ្យាសាស្ត្រ បច្ចេកទេស វប្បធម៌ និងសង្គម និងមាត្រា២៨ស្តីពី វិទ្យាសាស្ត្រ និងបច្ចេកវិទ្យាសម្រាប់ការអប់រំ បានតម្រូវឱ្យលើកកម្ពស់និងគាំទ្រដល់ការសិក្សាស្រាវជ្រាវ។ កត្តានេះជំរុញឱ្យក្រសួងអប់រំ យុវជន និងកីឡា កសាងគោលនយោបាយស្តីពីការអភិវឌ្ឍការស្រាវជ្រាវក្នុងវិស័យអប់រំ ដែលជាដំណាក់កាលថ្មីនៃការវិវឌ្ឍដ៏សំខាន់ក្នុងវិស័យអប់រំកម្ពុជា លើការផ្តោតកសាងធនធានមនុស្សប្រកបដោយសមត្ថភាពជំនាញនិងវិជ្ជាជីវៈសម្រាប់ទីផ្សារពលកម្មក្នុងស្រុក តំបន់ និងអន្តរជាតិ ដែលជាជ្រុងមួយនៃយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ដើម្បីឆ្លើយតបទៅនឹងការអភិវឌ្ឍក្នុងតំបន់និងសាកលលោកនាយុគសម័យសាកលភាវូបនីយកម្ម។

គោលនយោបាយស្តីពីការអភិវឌ្ឍការស្រាវជ្រាវក្នុងវិស័យអប់រំ ផ្តោតជាសំខាន់លើការពង្រឹងគុណភាពវិស័យអប់រំ ការបង្កើនចំណេះដឹងថ្មីៗ និងការអភិវឌ្ឍសង្គមសេដ្ឋកិច្ច និងវប្បធម៌ ដែលមានខ្លឹមសារ **ទីមួយ** ជានាឱ្យមានការស្រាវជ្រាវ នៅតាមគ្រឹះស្ថានឧត្តមសិក្សាក្នុងគ្រប់វិស័យនិងមុខជំនាញសិក្សា **ទីពីរ** ជំរុញការកសាងសមត្ថភាពស្រាវជ្រាវនិងអភិវឌ្ឍសមត្ថភាពស្រាវជ្រាវ នៅតាមគ្រឹះស្ថានឧត្តមសិក្សា **ទីបី** ធានាការគោរពក្រមសីលធម៌ ស្រាវជ្រាវ ការការពារស្នាដៃ និងការផ្សព្វផ្សាយលទ្ធផលស្រាវជ្រាវ និង**ទីបួន** ជំរុញការប្រើប្រាស់លទ្ធផលស្រាវជ្រាវ សម្រាប់ការបង្កើតចំណេះដឹងថ្មីនិងកិច្ចអភិវឌ្ឍ។

គោលនយោបាយនេះអាចសម្រេចចក្ខុវិស័យ គោលដៅ និងគោលបំណងរបស់ខ្លួនតាមរយៈយុទ្ធសាស្ត្រនិងការអនុវត្ត។ យុទ្ធសាស្ត្រចំនួនប្រាំពីរត្រូវបានតាក់តែងឡើង ហើយតម្រូវឱ្យមានការចូលរួមពីអង្គភាពពាក់ព័ន្ធជាច្រើន ជាពិសេសគឺការបង្កើតគណៈកម្មាធិការអភិវឌ្ឍការស្រាវជ្រាវក្នុងវិស័យអប់រំ(គ.អ.ស.) ដែលជាអង្គភាពទទួលខុសត្រូវផ្ទាល់ក្នុងការអភិវឌ្ឍក្របខណ្ឌច្បាប់និងយន្តការនានាដើម្បីជំរុញឱ្យការអភិវឌ្ឍគោលនយោបាយនេះសម្រេចជោគជ័យ។

ក្រសួងអប់រំ យុវជន និងកីឡាសង្ឃឹមយ៉ាងមុតមាំថា អង្គភាព ស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍនានានឹងចូលរួមជួយគាំទ្រគោលនយោបាយនេះឱ្យទទួលបានជោគជ័យ ដើម្បីជាគុណប្រយោជន៍ក្នុងការរួមចំណែកពង្រឹងគុណភាពឧត្តមសិក្សានៅកម្ពុជា។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែសីហា ឆ្នាំ២០១០

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

# សេចក្តីផ្តើម

ឧត្តមសិក្សាត្រូវបានចាត់ទុកថាជាអ្នកដើរតួនាំមុខផងនិងជាអ្នកឆ្លើយតបផងទៅនឹងបាតុភូតសាកលភាវូបនីយកម្ម។ ការបណ្តុះបណ្តាលធនធានមនុស្សកម្រិតខ្ពស់នៅតាមគ្រឹះស្ថានឧត្តមសិក្សាមានតួនាទីជាគន្លឹះក្នុងការជំរុញការរីកលូតលាស់របស់ប្រទេសនីមួយៗ។ គំរូបទពិសោធជាក់ស្តែងធ្លាប់បានកើតមានរួចមកហើយចំពោះប្រទេសអភិវឌ្ឍឈានមុខនាពេលបច្ចុប្បន្ន។ និន្នាការសាកលភាវូបនីយកម្មបាននាំមកនូវកាលានុវត្តភាពនិងការប្រឈមនានាចំពោះវិស័យអប់រំកម្ពុជា។ ការប្រឈមសម្រាប់ការអប់រំឧត្តមសិក្សាមានដូចជាការពង្រីកលទ្ធភាព ស្រូបនិស្សិតចូលរៀនឱ្យបានច្រើននិងគ្រប់ទីកន្លែង ការអភិវឌ្ឍការស្រាវជ្រាវ និងការផលិតចំណេះដឹង ដើម្បីរៀបចំកសាងសង្គមនិងសេដ្ឋកិច្ចនៃចំណេះដឹង ស្វ័យភាព និងគណនេយ្យភាព។ គ្រឹះស្ថានឧត្តមសិក្សា សេរីភាពនៃការសិក្សាជាន់ខ្ពស់ អភិបាលកិច្ច កម្មសិទ្ធិបញ្ញា គុណវុឌ្ឍិវិជ្ជាជីវៈ តំបន់នីយកម្ម និងអន្តរជាតិនីយកម្មឧត្តមសិក្សា សុទ្ធសឹងជាបញ្ហាដែលយើងកំពុងប្រឈមនិងយកចិត្តទុកដាក់គិតគូរដោះស្រាយពីព្រោះបញ្ហាគុណភាពអប់រំ គឺជាគន្លឹះនិងសំយោគបំផុត។

ការអប់រំសម្រាប់គោលដៅអភិវឌ្ឍជាតិប្រកបដោយចីរភាពទាមទារឱ្យយើងយកចិត្តទុកដាក់បន្ថែមទៀតដល់ការជំរុញនិងធ្វើឱ្យប្រសើរឡើងដល់យុទ្ធសាស្ត្រអប់រំនានា និងអភិវឌ្ឍសមត្ថភាពស្រាវជ្រាវ នៅតាមគ្រឹះស្ថានឧត្តមសិក្សានៅទូទាំងប្រទេស។ បច្ចុប្បន្នដោយនៅខ្វះខាត ផ្នែកធនធានការអប់រំ គ្រឹះស្ថានឧត្តមសិក្សានៅកម្ពុជានៅតែផ្តោតការយកចិត្តទុកដាក់សំខាន់ទៅលើការបង្រៀនច្រើនជាងការស្រាវជ្រាវនិងផ្តល់សេវាកម្មវិជ្ជាជីវៈជំនាញ។ ការកសាងវប្បធម៌ស្រាវជ្រាវក្នុងវិស័យអប់រំ គឺជានិន្នាការថ្មីមួយដែលត្រូវមានការជំរុញលើកទឹកចិត្តបំផុត សំដៅការកសាងធនធានមនុស្សកម្រិតខ្ពស់នៅកម្ពុជា ដោយមានគំនិតច្នៃប្រឌិតនិងការទទួលខុសត្រូវខ្ពស់ ប្រកបដោយសមត្ថភាព ការត្រិះរិះត្រឹមត្រូវ និងសកម្មភាពជាវិជ្ជមាន។

គ្រឹះស្ថានឧត្តមសិក្សាគប្បីត្រូវបានផ្តល់នូវកាលានុវត្តភាព និងការលើកទឹកចិត្តជំរុញការស្រាវជ្រាវសម្រាប់និស្សិត សាស្ត្រាចារ្យ និងអ្នកស្រាវជ្រាវ បន្តជំរុញរៀបចំការផ្តល់សេវាកម្មស្រាវជ្រាវនិងវិជ្ជាជីវៈជំនាញ ចូលរួមក្នុងវេទិកាស្រាវជ្រាវវិទ្យាសាស្ត្រនានាក្នុង និងក្រៅប្រទេស។

ច្បាប់ស្តីពីការអប់រំ មាត្រា១៨ វាក្យខណ្ឌទី២ចែងថា៖ « ការអប់រំឧត្តមសិក្សាត្រូវបណ្តុះបណ្តាលបុគ្គលិកលក្ខណៈពេញលេញ និងជំរុញការស្រាវជ្រាវផ្នែកវិទ្យាសាស្ត្របច្ចេកទេស វប្បធម៌ និងសង្គម ដើម្បីឱ្យមានសមត្ថភាពខ្ពស់ទាំងចំណេះដឹង ជំនាញ សីលធម៌ គំនិតច្នៃប្រឌិត គំនិតបង្កើតថ្មី និងស្មារតី សហគ្រិនភាព សម្រាប់អភិវឌ្ឍប្រទេសជាតិ។ » និងមាត្រា២៨ វាក្យខណ្ឌទី១ចែងថា៖ « រដ្ឋត្រូវលើកកម្ពស់និងគាំទ្រដល់ការសិក្សាស្រាវជ្រាវ ការអភិវឌ្ឍការច្នៃប្រឌិត និងការផលិតដែលមានលក្ខណៈវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាសម្រាប់ការអប់រំដែលឆ្លើយតបទៅនឹងទីផ្សារពលកម្ម និងស្របតាមសាកលភាវូបនីយកម្មដើម្បីលើកស្ទួយសមត្ថភាពធនធានមនុស្ស និងជំរុញការអភិវឌ្ឍប្រទេសជាតិ។ » ច្បាប់នេះបានបញ្ជាក់ច្បាស់អំពីអត្ថប្រយោជន៍នៃការស្រាវជ្រាវក្នុងវិស័យអប់រំ ដែលជាចលករគន្លឹះមួយដើម្បីឆ្ពោះទៅរកការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមប្រកបដោយចីរភាព។

គោលនយោបាយស្តីពីការអភិវឌ្ឍការស្រាវជ្រាវក្នុងវិស័យអប់រំនឹងនាំមកនូវដំណាក់កាលមួយថ្មីក្នុងការធ្វើកំណែទម្រង់ឧត្តមសិក្សា ដើម្បីពង្រឹងគុណភាពអប់រំនៅកម្ពុជា សំដៅនាំធនធានមនុស្សរបស់ប្រទេសជាតិឈានចូលដោយរលូនទៅក្នុងបរិបទសាកលភាវូបនីយកម្ម និងក្នុងការសម្រេចគោលដៅអភិវឌ្ឍសហស្សវត្សរ៍កម្ពុជានិងពិភពលោក។

# ជំពូកទី១
# ចក្ខុវិស័យ គោលដៅ និងគោលបំណង

## I- ចក្ខុវិស័យ

កសាងឱ្យមានធនធានមនុស្សដែលមានសមត្ថភាពខ្ពស់ ទាំងចំណេះដឹង ជំនាញ សីលធម៌ គំនិតច្នៃប្រឌិត គំនិតបង្កើតថ្មី និងស្មារតីសហគ្រិនភាពសម្រាប់រួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចសង្គមកម្ពុជាប្រកបដោយចីរភាពនៅក្នុងបរិបទសាកលភាវូបនីយកម្ម។

## II- គោលដៅ

គោលនយោបាយនេះមានគោលដៅកសាងវប្បធម៌ស្រាវជ្រាវ នៅតាមគ្រឹះស្ថានឧត្តមសិក្សានានា សំដៅធានាឱ្យស្ថាប័នទាំងនោះក្លាយទៅជាគ្រឹះស្ថានសំខាន់ សម្រាប់ផ្សារភ្ជាប់ការបណ្តុះបណ្តាល និងការស្រាវជ្រាវដើម្បីអភិវឌ្ឍប្រទេសជាតិ។

## III- គោលបំណង

គោលនយោបាយនេះមានគោលបំណងដូចខាងក្រោម៖

១. ពង្រឹងគុណភាពអប់រំនៅឧត្តមសិក្សាកម្ពុជាតាមរយៈការប្រែក្លាយគ្រឹះស្ថានឧត្តមសិក្សានីមួយៗឱ្យទៅជាមជ្ឈមណ្ឌលស្រាវជ្រាវសម្រាប់ការអភិវឌ្ឍនិងបង្កើតចំណេះដឹងថ្មី។

២. ពង្រីកលទ្ធភាពកិច្ចសហប្រតិបត្តិការឱ្យបានទូលាយក្នុងក្របខណ្ឌជាតិនិងអន្តរជាតិ។

៣. លើកកម្ពស់សមត្ថភាពធនធានមនុស្សប្រកបដោយគំនិតច្នៃប្រឌិតនិងនវានុវត្តន៍។

# ជំពូកទី២
# គោលនយោបាយ

គោលនយោបាយស្តីពីការអភិវឌ្ឍការស្រាវជ្រាវក្នុងវិស័យអប់រំ មានខ្លឹមសារដូចខាងក្រោម៖

- ធានាឱ្យមានការស្រាវជ្រាវ នៅតាមគ្រឹះស្ថានឧត្តមសិក្សាក្នុងគ្រប់វិស័យនិងមុខជំនាញសិក្សា

- ជំរុញការកសាងសមត្ថភាពអ្នកស្រាវជ្រាវនិងអភិវឌ្ឍសមត្ថភាពស្រាវជ្រាវនៅតាមគ្រឹះស្ថានឧត្តមសិក្សា

- ធានាការគោរពក្រមសីលធម៌ស្រាវជ្រាវ ការការពារស្នាដៃ និងការផ្សព្វផ្សាយលទ្ធផលស្រាវជ្រាវ

- ជំរុញការប្រើប្រាស់លទ្ធផលស្រាវជ្រាវ សម្រាប់ការបង្កើតចំណេះដឹងថ្មីនិងកិច្ចអភិវឌ្ឍ។

## ជំពូកទី៣
## យុទ្ធសាស្ត្រនិងការអនុវត្ត

*យុទ្ធសាស្ត្រនិងការអនុវត្តខាងក្រោមនេះ ជានាឱ្យសម្រេចបាននូវចក្ខុវិស័យ គោលដៅ និងគោលបំណងនៃគោលនយោបាយខាងលើ៖*

**I- យុទ្ធសាស្ត្រ**

**យុទ្ធសាស្ត្រទី១ : អភិវឌ្ឍន៍សមត្ថភាពស្រាវជ្រាវ**

*- ជំរុញយ៉ាងសកម្មនូវកម្រិត និងការបណ្ដុះបណ្ដាលសមត្ថភាពស្រាវជ្រាវនៅក្នុងវិស័យគន្លឹះដែលឆ្លើយតបទៅនឹងអាទិភាពជាតិនានា*

*- លើកទឹកចិត្តអ្នកស្រាវជ្រាវដែលពូកែ មានស្នាដៃលេចធ្លោក្នុងប្រទេស*

*- អភិវឌ្ឍសមត្ថភាព អ្នកស្រាវជ្រាវតាមគ្រប់រូបភាពនៃប្រព័ន្ធអប់រំកម្ពុជា។*

**យុទ្ធសាស្ត្រទី២ : គុណភាពស្រាវជ្រាវ**

*- លើកទឹកចិត្តឱ្យមានការឡើងបង្ហាញអត្ថបទស្រាវជ្រាវ នៅតាមសន្និសីទជាតិនិងអន្តរជាតិ*

*- គាំទ្រឱ្យមានការរៀបចំសន្និសីទ ទាំងកម្រិតជាតិនិងអន្តរជាតិនៅកម្ពុជា*

*- ជំរុញឱ្យមានរចនាសម្ព័ន្ធសមស្រប ដែលនឹងលើកទឹកចិត្តឱ្យមានជំនួបទូលាយរវាងអ្នកស្រាវជ្រាវនានា មកពីមុខជំនាញផ្សេងៗ*

*- ផ្ដល់ឱកាសសម្រាប់ការបោះពុម្ពផ្សាយ ដែលមានការត្រួតពិនិត្យជាក្រុមនៅក្នុងស្រុក*

*- លើកទឹកចិត្តអ្នកស្រាវជ្រាវឱ្យស្រាវជ្រាវអំពីប្រធានបទពាក់ព័ន្ធនឹងប្រទេសកម្ពុជា និងការបោះពុម្ពផ្សាយនៅកម្ពុជា*

*- គាំទ្រការរៀបចំទស្សនាវដ្ដីស្រាវជ្រាវអេឡិចត្រូនិកតាមគេហទំព័រ។*

**យុទ្ធសាស្ត្រទី៣ : ការស្រាវជ្រាវរួមគ្នា**

*- ជំរុញយ៉ាងសកម្មនូវកិច្ចសហប្រតិបត្តិការរវាងស្ថាប័នស្រាវជ្រាវនានា ជាពិសេសរវាងវិស័យឯកជននិងសាធារណៈ និងរវាងអ្នកស្រាវជ្រាវជាតិនិងអន្តរជាតិ*

*- គាំទ្រគម្រោងស្រាវជ្រាវពាក់ព័ន្ធនឹងមុខវិជ្ជាសិក្សាច្រើនចម្រុះគ្នានិងអន្តរជំនាញ។*

**យុទ្ធសាស្ត្រទី៤ : របាយការណ៍ស្រាវជ្រាវ**

*- អភិវឌ្ឍយន្តការមួយចំនួន ដើម្បីបង្កើននូវវប្បធម៌រាយការណ៍លទ្ធផលស្រាវជ្រាវជាទៀងទាត់ និងសមស្របលើគ្រប់វិស័យទាំងអស់*

*- អភិវឌ្ឍប្រព័ន្ធគ្រប់គ្រងទិន្នន័យស្រាវជ្រាវ និងរាយការណ៍ព័ត៌មានពិស្ដាររួម ។*

**យុទ្ធសាស្ត្រទី៥ : ក្រមសីលធម៌ស្រាវជ្រាវនិងការអនុញ្ញាតឱ្យស្រាវជ្រាវ**

*- រៀបចំលិខិតបទដ្ឋាននិងផ្តល់ព័ត៌មានដល់និស្សិត បុគ្គលិក និងអ្នកស្រាវជ្រាវ អំពីការលួចចម្លងនិងការការពារស្នាដៃ*

*- យកចិត្តទុកដាក់គិតគូរនិងគោរពដល់វិស័យក្រមសីលធម៌ស្រាវជ្រាវទាំងឡាយ ដែល មានបកស្រាយនៅក្នុងអនុសញ្ញាអន្តរជាតិនានា និងក្របខណ្ឌច្បាប់ជាតិមួយចំនួន ដែលមានជាធរមាននិងកំពុងអភិវឌ្ឍ*

*- រៀបចំនិងអភិវឌ្ឍប្រព័ន្ធសម្រាប់ការអនុញ្ញាតការស្រាវជ្រាវក្នុងគោលបំណង ធានាដល់ការអនុវត្តតាមគោលការណ៍ អំពីក្រមសីលធម៌ស្រាវជ្រាវ។*

**យុទ្ធសាស្ត្រទី៦ : សហប្រតិបត្តិការអន្តរជាតិ**

*- បង្កឱកាសឱ្យអ្នកស្រាវជ្រាវអន្តរជាតិដែលមានវិជ្ជាជីវៈសហការជាមួយអ្នកស្រាវជ្រាវកម្ពុជា*

*- ជំរុញការគោរពក្រមសីលធម៌ស្រាវជ្រាវក្នុងចំណោមអ្នកស្រាវជ្រាវប្រតិបត្តិការនៅកម្ពុជា*

*- លើកទឹកចិត្តកិច្ចសហប្រតិបត្តិការជាតិ និងអន្តរជាតិ តាមរយៈការផ្លាស់ប្តូរលទ្ធផល និងជំនាញការស្រាវជ្រាវ*

*- ជំរុញកិច្ចសហការជាមួយគ្រឹះស្ថានសិក្សាស្រាវជ្រាវ និងសាកលវិទ្យាល័យ*

**យុទ្ធសាស្ត្រទី៧ : ការសិក្សាទីផ្សារនិងការអភិវឌ្ឍ**

*- លើកទឹកចិត្តឱ្យអ្នកស្រាវជ្រាវទទួលបានអត្ថប្រយោជន៍ សមស្របពីការងារស្រាវជ្រាវ*

*- លើកទឹកចិត្តការងារស្រាវជ្រាវឱ្យផ្សារភ្ជាប់ជាមួយនឹងគំនិតផ្តួចផ្តើមថ្មីៗផ្នែក វិទ្យាសាស្ត្រ បច្ចេកវិទ្យា សេដ្ឋកិច្ច សង្គម និងវប្បធម៌*

*- សម្របសម្រួលសម្ព័ន្ធភាពរវាងស្ថាប័នស្រាវជ្រាវ និងវិស័យផលិតកម្ម និងសេវាកម្មនានា។*

**II- ការអនុវត្ត**

*ត្រូវបង្កើតគណៈកម្មាធិការអភិវឌ្ឍការស្រាវជ្រាវក្នុងវិស័យអប់រំ (គ.អ.ស.) ដែលមានភារកិច្ចៈ*

*- សម្របសម្រួលបច្ចេកទេសនិងការទទួលខុសត្រូវរបស់អង្គភាព ស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍ*

- ជំរុញការងារស្រាវជ្រាវថ្នាក់ជាតិលើវិស័យអប់រំនិងគ្រឹះស្ថានឧត្តមសិក្សា
- ស្វែងរកនិងគ្រប់គ្រងធនធាន ដើម្បីទ្រទ្រង់សកម្មភាព ដំណើរការរបស់ គ.អ.ស.
- ជំរុញការស្រាវជ្រាវតាមរយៈការបង្កើតវប្បធម៌ស្រាវជ្រាវនៅក្នុងវិស័យអប់រំ
- អភិវឌ្ឍក្របខណ្ឌច្បាប់និងយន្តការនានាចាំបាច់ ដើម្បីឱ្យ គ.អ.ស. មានសិទ្ធិនិងកាតព្វកិច្ចក្នុងដំណើរការជំរុញ ការអនុវត្តគោលនយោបាយស្រាវជ្រាវនេះ ឱ្យមានប្រសិទ្ធភាព
- ជំរុញការអភិវឌ្ឍ គោលនយោបាយស្តីពី ការអភិវឌ្ឍការស្រាវជ្រាវក្នុងវិស័យអប់រំ នៅតាមគ្រឹះស្ថានឧត្តមសិក្សា និងស្ថាប័នស្រាវជ្រាវពាក់ព័ន្ធ។

## សន្និដ្ឋាន

គោលនយោបាយស្តីពីការអភិវឌ្ឍការស្រាវជ្រាវក្នុងវិស័យអប់រំនឹងនាំឱ្យមានការអភិវឌ្ឍសមត្ថភាពស្រាវជ្រាវ នៅតាមគ្រឹះស្ថានឧត្តមសិក្សាដែលជាកត្តាគន្លឹះបំផុតសម្រាប់លើកកម្ពស់គុណភាព និងភាពទាក់ទងការអប់រំ ដើម្បីជំរុញឱ្យកាន់តែមានភាពងាយស្រួលដល់កម្លាំងពលកម្មកម្ពុជា ក្នុងការអភិវឌ្ឍសេដ្ឋកិច្ច សង្គមប្រកបដោយប្រសិទ្ធភាព សក្តិសិទ្ធិភាព និងចីរភាពក៏ដូចជាក្នុងការបង្កើន សក្តានុពលភាពជាតិ ដើម្បីធ្វើសមាហរណកម្មតំបន់និងអន្តរជាតិ នាយុគសម័យ សាកលភាវូបនីយកម្ម។

រាជរដ្ឋាភិបាលកម្ពុជាបានខិតខំកៀរគរ ទាក់ទាញ គ្រប់គ្រង និងប្រើប្រាស់លទ្ធភាពធនធានដើម្បីកសាងនិងអភិវឌ្ឍវប្បធម៌ និងសមត្ថភាពស្រាវជ្រាវក្នុងវិស័យអប់រំ ដោយយកគោលការណ៍ការអប់រំដើម្បីអភិវឌ្ឍប្រកបដោយចីរភាពធ្វើជាមូលដ្ឋាន។

ការរៀបចំលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងការអនុវត្តគោលនយោបាយស្តីពីការអភិវឌ្ឍការស្រាវជ្រាវក្នុងវិស័យអប់រំនឹងត្រូវធ្វើឡើងជាបន្តបន្ទាប់ដូចជា៖
- រៀបចំយន្តការនិងបទដ្ឋានគតិយុត្តសម្រាប់ការរៀបចំនិងការប្រព្រឹត្តទៅរបស់ គ.អ.ស.
- រៀបចំផែនការសម្រាប់ទ្រទ្រង់ការអភិវឌ្ឍការស្រាវជ្រាវរយៈពេលខ្លី មធ្យម និងវែង។

ក្រសួង ស្ថាប័ននិងអាជ្ញាធរពាក់ព័ន្ធគ្រប់លំដាប់ថ្នាក់ត្រូវរួមចំណែកជំរុញនិងអនុវត្តគោលនយោបាយស្តីពីការអភិវឌ្ឍការស្រាវជ្រាវក្នុងវិស័យអប់រំ ហើយត្រូវផ្សព្វផ្សាយឱ្យបានទូលំទូលាយដល់អ្នកសិក្សា អ្នកស្រាវជ្រាវ និងដៃគូអភិវឌ្ឍនានា ក្នុងគោលបំណង លើកទឹកចិត្ត ឱ្យមានការចូលរួមអនុវត្តបានជោគជ័យ។

រៀបចំនិងឧបត្ថម្ភការបោះពុម្ពផ្សាយដោយ

Ministry of Education,
Youth and Sport

United Nations
Educational. Scientific and
Cultural Organization